ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　　ជាតិ　　សាសនា　　ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៤៤

ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០០

សាលដីកា

លេខ : ៦០

ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០១

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ:

១.ឯកឧត្តម ឌិត មន្ទី ប្រធាន

២.លោក ប៉េន ស៊ិន ចៅក្រម

៣.លោក ស៊ិន ឌឹម ចៅក្រម

៤.លោក ជីវ កេង ចៅក្រម

៥.លោក យស់ សូខឿន ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

អ្នកស្រី ភួង ចន្ធា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ២៥ ក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៨១ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ មិន ស្រី អាយុ ៣៧ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើការនៅក្រុមហ៊ុន មានទីលំនៅភូមិកំពង់សំណាញ់ ឃុំកំពង់សំណាញ់ ស្រុក - តាខ្មៅ ខេត្តកណ្តាល ។ ឪពុកឈ្មោះ អូ អូក "ស" ម្តាយឈ្មោះ កេត ចារុង "ស" ប្តីឈ្មោះ ហង្ស សាល មានកូន ០២ នាក់ ។

- និងចុងបណ្តឹងសាទុក្ខឈ្មោះ ជា សុខនាង អាយុ ៤១ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើការនៅផលផលខេត្តកណ្តាល មានទីលំនៅភូមិក្រពើហារ ឃុំព្រែកឫស្សី - ស្រុកតាខ្មៅ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ជា សឿន "រស់" ម្តាយឈ្មោះកុល មុំក "រស់" ប្រពន្ធឈ្មោះ ស ផល្លា មានកូន ០៤ នាក់ ។

កម្មវត្ថុ: ប្តឹងទាមទារសុំបែងចែកដី

បាន ឃើញបណ្តឹងសាទុក្ខលេខ ១៣៨ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០០ របស់ឈ្មោះ មិន ស្រី ប្តឹងមិនសុខចិត្តនិងសាលដីកាលេខ ២៥ "ក" ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បាន ឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៧.៥.១៩៩៩ របស់ដើមចោទ ប្តឹងសុំបែងចែកដីលំនៅដ្ឋាន ដោយសំអាងហេតុថា ដីនេះជាទ្រព្យសម្បត្តិរួម ប្តីប្រពន្ធរវាងខ្លួននឹងឈ្មោះ មិន ស្រី ដោយមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ជាទ្រព្យសម្បត្តិរួម ។

បាន ឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤០ "ព" ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៩ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១.ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៧.៥.៩៩ របស់ដើមចោទឈ្មោះ ជា សុខនាង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២.បង្គាប់អោយនារី មិន ស្រី បែងចែកដីលំនៅដ្ឋានដែលមានទំហំក្បាលដី២៣ម៉ែត្រ កណ្តាលដី ២០,៩ ម៉ែត្រ កន្ទុយដី២០,៨ ម៉ែត្រ បណ្តោយដី ៧៩ ម៉ែត្រ ស្ថិតក្នុងភូមិកំពង់សំណាញ់ ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល ដែលជាទ្រព្យសម្បត្តិរួមសម្រាប់អោយទៅឈ្មោះជា សុខនាង ពាក់កណ្តាលផ្នែកខាងកើត ដោយពុះតាមបណ្តោយដីពីជើងទៅត្បូង និងបង្គាប់អោយនារី មិន ស្រី រើផ្ទះ និងផ្ទះបាយចេញពីដីជាចំណែករបស់ឈ្មោះ ជា សុខនាង ទៅលើដីចំណែករបស់ខ្លួននៅពេលសាលក្រមនេះចូលជាស្ថាពរ ។

- តាមបញ្ញត្តិមាត្រា ៧០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៥៦ក្រ ចុះថ្ងៃទី ២៦.០៧.៨៩ ។

៣.រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០ រៀល ដែលដើមចោទបានបង់ ដោយប្រាក់នេះ ចំណាយលើកិច្ចស៊ើបសួរ ពន្ធចុះបញ្ជីក្តី និង ពន្ធតាំង ។

៤. សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទនិងចុងចម្លើយ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បាន ឃើញបណ្តឹងឧទ្ធរណ៍លេខ ១០៤ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ របស់ឈ្មោះ មិន ស្រី ប្តឹងមិនសុខចិត្ត និងសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

បាន ឃើញសាលដីការដ្ឋប្បវេណីលេខ ២៥ "ក" ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៨.១០.៩៩ របស់ឈ្មោះ មិន ស្រី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ នឹងគតិច្បាប់ ។

២.តំកល់សាលក្រមលេខ ៥០ "ព" ចុះថ្ងៃទី ២៦.៨.៩៩ របស់តុលាការខេត្តកណ្ដាល ទុកជាគ្មានតម្រូវពេញទាំងមូល ។

៣.រឹបអូសប្រាក់ប្រដាប់ក្ដីដាក់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹង ២៥៥០ រង្វាន់ក្រឡាបញ្ជី ៤៥០ រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០ រៀល អាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០ រៀល ។

៤.សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ហេតុ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០០ របស់ឈ្មោះ មិន ស្រី ប្ដឹងមិនសុខចិត្តនិងសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០០ របស់ឈ្មោះ មិន ស្រី ជាម្ចាស់បណ្ដឹងសាទុក្ខ ។

បានឃើញសារណាតបចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០០ របស់ឈ្មោះ - ជា សុខនាង ជាចុងបណ្ដឹងសាទុក្ខ ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអ៊ា :

- បណ្ដឹងសាទុក្ខរបស់ចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ ២៥ "ក" ចុះថ្ងៃទី ២៤.០២.២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេចតាមច្បាប់។

បានស្ដាប់ចម្លើយរបស់ឈ្មោះ មិន ស្រី ជាចុងចម្លើយ និងជាម្ចាស់បណ្ដឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយថា បានជាខ្លួនប្ដឹងសាទុក្ខមកតុលាការកំពូល មកពីសាលាឧទ្ធរណ៍និងតុលាការខេត្តកណ្ដាល សំរេចសេចក្ដីមិនត្រឹមត្រូវ ព្រោះថា ដីនេះខ្លួនសុំទុកអោយកូនទាំងពីរនាក់ ដល់ពេលវាមានប្ដីប្រពន្ធ ។ ដីនេះរដ្ឋជាអ្នកបែងចែកអោយខ្លួន ហើយប្ដីខ្លួនទើបប្ដឹងសុំបែងចែកដីនេះនៅពេលដីទឡ្ហើងថ្លៃ ។ ខ្លួនសុំស្នើមពរតុលាការសុំទុកដីនេះអោយកូនខ្លួនទាំងពីរនាក់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ជា សុខនាង ជាដើមចោទ និងជាចុងបណ្ដឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយថា ដីនេះខ្លួនបានកាន់កាប់តាំងពីខ្លួននៅលីវរហូតមក ហើយពេលខ្លួនរៀបការក៏បានសង់ផ្ទះនៅលើដីនេះ ប៉ុន្តែក្រោយមករស់នៅមិនចុះសំរុងគ្នាក៏បានដាក់ពាក្យបណ្ដឹងទៅ - សង្កាត់ដើម្បីលែងលះប្ដីប្រពន្ធ ចំពោះកូនខ្លួនសុំសិទ្ធិគ្រប់គ្រងកូនប្រុសបង និងកូនស្រីទៅនៅខាង

ម្តាយ ហើយដីនេះខ្លួនសុំសិទ្ធិគ្រប់គ្រងពាក់កណ្តាលម្នាក់ ហេតុនេះសូមតុលាការពិចារណា ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

---

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ របស់អ្នកស្រី មិន ស្រី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការខេត្តកណ្តាលដែរ ដែលបានសម្រេចសេចក្តីបែងចែកដី ដោយពុំបានសម្រេចអំពីការលែងលះគ្នានិងពុំបានសម្រេចអំពីអំណាចមេបាលើកូនទាំងពីរនាក់នេះជាការពុំត្រឹមត្រូវទេ ពីព្រោះសារព្រមព្រៀងលែងលះគ្នាដែលធ្វើនៅមុខរដ្ឋអំណាចពុំអាចយកជាការបានឡើយ ចាំបាច់ត្រូវតែជាសមត្ថកិច្ចរបស់តុលាការដូចដែលមានចែងក្នុងមាត្រា ៤១និង ៥៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។ ហើយតាមអំណាចនៃការលែងលះទើបតុលាការអាចពិចារណានិងសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិនិង អំណាចមេបាបាន ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៥ "ក" ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១.ទទួលបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ របស់អ្នកស្រី មិន ស្រី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២.ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២៥ "ក" ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣.បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៤ ចុះថ្ងៃទី ២២. ខែ មិថុនា ឆ្នាំ-

២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤.រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ជា.សុខនាង បានបង់ជូនរួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។
- ចំណាយលើកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល

៥.សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៤ ខែ-មេសា ឆ្នាំ ២០០១ ។